# ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា
## ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍

១. លើកកម្ពស់សង្គមបរិយាបន្ន និងរាប់បញ្ចូលជនទេសន្តរប្រវេសន៍ក្នុងការឆ្លើយតប និងការស្តារឡើងវិញទាក់ទងនឹងមេរោគកូវីដ-១៩

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តបង្កើនកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងកិច្ចសហការជាមួយភ្នាក់ងារពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលសុខភាពពលករទេសន្តរប្រវេសន៍ទៅក្នុងសេវាគ្របដណ្តប់សុខភាពជាតិ តាមរយៈការអនុវត្ត «គោលនយោបាយសុខភាពជនទេសន្តរប្រវេសន៍» និងផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០២១-២០៣០ រាជរដ្ឋាភិបាលកម្ពុជានឹងដំណើរការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រជាតិ ដោយប្រើវិធីសាស្ត្រផ្តោតលើរដ្ឋាភិបាល និងសង្គមទាំងមូល។ នៅក្នុងវេទិកាវាយតំលៃទេសន្តរប្រវេសន៍អន្តរជាតិបន្ទាប់ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ២០២៦ រាជរដ្ឋាភិបាលកម្ពុជានឹងអាចបង្ហាញពីភាពរីកចំរើនជាក់លាក់ពាក់ព័ន្ធនឹងសេវាសុខភាពគ្របដណ្តប់សកល និងការទទួលបានសេវាសុខភាពចាំបាច់នានារបស់ជនទេសន្តរប្រវេសន៍។

២. លើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ និងសុវត្ថិភាព

គោលបំណងអាទិភាពចំនួនបីដែលរួមមានគោលបំណងទី ១ ទី ១១ និងទី ២៣ ត្រូវបានជ្រើសរើស ជាជំហានគន្លឹះឆ្ពោះទៅមុខ ហើយកម្ពុជានឹងបន្តឆ្លើយតបនឹងគោលបំណងដែលពាក់ព័ន្ធផ្សេងៗទៀតតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុង តំបន់ និងសកលលោក។ កម្ពុជានឹងសម្រេចបានផែនការអនុវត្តជាតិ GCM ឆ្នាំ២០២៣-២០២៥ នឹងជាបន្តបន្ទាប់ អនុវត្តផែនការសកម្មភាពរយៈពេល ២ឆ្នាំ របស់ខ្លួនដោយមានការចូលរួមពីក្រសួងសាមី និងអ្នកពាក់ព័ន្ធផ្សេងៗទៀតតាមរយៈសកម្មភាពរងរបស់ខ្លួន ដែលនេះជាវិធីសាស្ត្រផ្តោតលើរដ្ឋាភិបាល និងសង្គមទាំងមូល។ នៅក្នុងវេទិកាវាយតំលៃទេសន្តរប្រវេសន៍អន្តរជាតិលើកទីពីរ (IMRF) រាជរដ្ឋាភិបាលកម្ពុជានឹងមានលទ្ធភាពបង្ហាញពីលទ្ធផលជាក់ស្តែង និងភាពរីកចំរើន លើអភិបាលកិច្ចទេសន្តរប្រវេសន៍ដែលនឹងសម្រេចបានតាមរយៈផែនការជាតិអនុវត្ត GCM ។

៣. ធានាថា កុមារដែលកំពុងចល័ត និងកូនរបស់ជនទេសន្តរប្រវេសន៍ទទួលបានការការពារល្អប្រសើរ

បង្កើតកិច្ចសហប្រតិបត្តិការដ៏រឹងមាំជាមួយប្រទេសគោលដៅ ដើម្បីផ្តល់ការគាំទ្រច្បាស់លាស់មួយ ដល់ជនទេសន្តរប្រវេសន៍ដែលពុំមានឯកសារត្រឹមត្រូវ រួមមានទាំងមនុស្សពេញវ័យ និងកុមារដែលពុំមានមនុស្សពេញវ័យនៅជាមួយ និងកូនរបស់ជនទេសន្តរប្រវេសន៍ដែលកើតនៅបរទេស ដើម្បីទទួលបាន និងរក្សាឯកសារអត្រានុកូលដ្ឋានរបស់ពួកគេ ជាពិសេសការចុះសំបុត្រកំណើត។ ឯកសារអត្រានុកូលដ្ឋានអាចពួកគេទទួលបានសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងសេវាមូលដ្ឋានចាំបាច់នានា រួមមានការអប់រំ និងការងារសមរម្យ ព្រមទាំងអាចឱ្យពួកគេគេចផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច ការរំលោភបំពាន ការជួញដូរ និង/ឬក្លាយជាជនភៀសខ្លួន ជនគ្មានសញ្ជាតិ និង/ឬទាសករ។ អាជ្ញាធរដែលជាស្ថានកុងស៊ុលនឹងដើរតួនាទីយ៉ាងសំខាន់

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ដោយសារតែស្ថាប័ននេះអាចដើរតួជាមន្ត្រីអត្រានុកូលដ្ឋាន។ នៅក្នុងវេទិកាវាយតំលៃទេសន្តរប្រវេសន៍អន្តរជាតិលើកទីពីរ (IMRF) រាជរដ្ឋាភិបាលកម្ពុជានឹងមានលទ្ធភាពបង្ហាញពីលទ្ធផលជាក់ស្តែងដែលសម្រេចបាន។

## Pledges of the Royal Government of Cambodia

1. **Promoting inclusive societies and including migrants in COVID-19 response and recovery**

   The Royal Government of Cambodia (RGC), will continue to increase national efforts and cooperation with stakeholders to include migrant workers in the national healthcare coverage through the implementation of " the National Policy on Migrant Health" and its 10 years Strategic Plan (2021-2030), by using a whole of government and society approach. By the next IMRF (2026), Cambodia will be able to demonstrate concrete improvements in universal health coverage and migrants' access to essential health services.

2. **Promoting safe and regular migration**

   Three priority objectives are selected including objectives 1, 11 and 23 to be key step forward, and will address other relevant objectives by strengthening internal, regional and global cooperation. Cambodia will achieve its National GCM Implementation Plan (2023-2025), followed by its two-year Action Plan, by involving individual ministry and other stakeholders in sub-actions, as a whole government and society approach. By the next IMRF, Cambodia will be able to demonstrate concrete results and improvements.

3. **To ensure that Children on the move, migrant's children are also well protected**

   Build up a strong collaboration with destination countries to provide clear support to migrants in undocumented status, both adults, children unaccompanied - and migrants' children born abroad, to receive and keep their civil status documents especially birth registration; so that they can exercise their basic rights, and to access basic services, including education and decent work, and to enable them to escape from subjecting to any forms of exploitation, violation, trafficking, and/or becoming displace persons, stateless people and/or slave. The consular authorities will play a critical role to remedy these obstacles, as they can act as civil registrar. By the next IMRF, Cambodia will be able to demonstrate concrete results achieved.